**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤២៣៤
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩
សំណុំរឿងស៊ើបសួរ
លេខ: ២៨៩៥
ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩
សំណុំរឿងជំនុំជម្រះ
លេខ: ៣៨៦៥
ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩
**សាលក្រមព្រហ្មទណ្ឌ**
លេខ: ៩៦ "ឃ"
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

-បានបើកសវនាការជាសាធារណៈ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ០៨ : ០០ នាទី (ព្រឹក) ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ លេខ: **៤២៣៤** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ដូចខាងក្រោម ៖

-ឈ្មោះ [redacted] **តូច** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅ ភូមិ [redacted] ខេត្តតាកែវ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ ការដ្ឋានសំណង់ផ្លូវលេខ:៥៩៨ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **អត** (រ) ម្តាយឈ្មោះ [redacted] **មុល** (រ) នៅលើវ ជានីតិជន។ (ក្នុងឃុំ)

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **គ្មាន** ។

+ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: **៦៧៦០ "ថ" ដ.ឃ.ដ** ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-ឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើតនៅ ភូមិ [redacted] ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ ការដ្ឋានសំណង់ ផ្លូវលេខ:៥៩៨ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **រស់** (រ) ម្តាយឈ្មោះ [redacted] **សុភា** (រ) នៅលើវ ជានីតិជន។ (ក្នុងឃុំ)

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **គ្មាន** ។

+ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: **៦៧៥៩ "ថ" ដ.ឃ.ដ** ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។



Scanned with CamScanner

ជាប់ចោទពីបទ ៖ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ជិតភ្លើងស្តុប បឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-លោក [redacted]

និងលោក [redacted] មានការិយាល័យឈ្មោះ **ក្រុមមេធាវី ភ្នំពេញ កម្ពុជា** មានការិយាល័យផ្ទះលេខ: ១៥E0E1 ផ្លូវលេខ:៤ កែងផ្លូវ៦ ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តូច ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ២០ និង ១៥ នាទី ល្ងាចដោយមានការដឹកនាំសម្របសម្រួល ពីលោកព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ការិយាល័យបច្ចេកទេស (ក៦) បានបង្ក្រាបករណី ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចជិតភ្លើងស្តុបបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឃាត់ខ្លួនបានជនសង្ស័យចំនួន **ពីរនាក់** មានឈ្មោះ [redacted] **តូច** ភេទប្រុស អាយុ ២៥ឆ្នាំ និង ឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២០ឆ្នាំ យកមកសាកសួរនៅមន្ទីរប្រឆាំងគ្រឿងញៀន រួចសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** របាយការណ៍សរុប លេខ: **១៩៣៣/១៩ រ.ប.ក** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ: **២៩២៥ អ.យ.ច** ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរ លេខ: **៣៧៣៥ អ.យ.ច** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាបង្គាប់ឱ្យរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន លេខ: **១១១០២ "ថ" ដ.ឃ.ដ** ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាបង្គាប់ឱ្យរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន លេខ: **១១១០១ "ថ" ដ.ឃ.ដ** ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ: **៥០៣២ "ថ" ដ.ដ** ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ឯកសារភស្តុតាងនានានៅក្នុងសំណុំរឿង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **តូច** បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួនព្រោះតែខ្លួនមានសារធាតុញៀន តែពុំមានគ្រឿងញៀនជាប់ខ្លួននោះទេ គ្រាន់តែប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ។

-ជនជាប់ចោទឈ្មោះ [redacted] **ឡុង** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនបានចូលលុយជាមួយឈ្មោះ [redacted] តូច ម្នាក់ មួយម៉ឺនរៀល ពេលមកដល់ក្តាន់ពីរក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ហើយសមត្ថកិច្ចមិនបានដកហូតអ្វីពីខ្លួននោះទេ។



Scanned with CamScanner

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ ក្រោយពីបានស្ដាប់ចម្លើយការសួរដេញដោលនាពេលសវនាការ និងបានពិនិត្យភស្ដុតាងក្នុងសំណុំរឿងរួចឃើញថា ជនជាប់ចោទឈ្មោះ [redacted] តូច ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឡុង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ បានសារភាពទទួលស្គាល់នូវអំពើរបស់ខ្លួន ថាពិតជាបាន **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន។ ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ដាពរលេខៈ **៣៧៣៥ អ.យ.ច** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ និងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថាៈ ស្នើសុំឱ្យតុលាការប្ដូរបទចោទពីមាត្រា **៤២** ទៅមាត្រា **៤៥** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន វិញ និងសុំឱ្យលោកចៅក្រមពិនិត្យសំណុំរឿងឱ្យច្បាស់ម្ដងទៀត ព្រោះថ្ងៃកើតហេតុនោះមិនទាន់មានបទល្មើសកើតឡើងទេ គឺកូនក្ដីខ្លួនបានប្រើប្រាស់គ្រឿងញៀនមុនកើតហេតុតែប៉ុណ្ណោះ។

## សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ឈ្មោះ [redacted] **តូច** បាននិយាយសម្ដីចុងក្រោយថា សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះរូបខ្លួនបានដឹងកំហុសហើយ ។

-ឈ្មោះ [redacted] **ឡុង** បាននិយាយសម្ដីចុងក្រោយថា សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះរូបខ្លួនបានដឹងកំហុសហើយ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្ដុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

១.តាមរបាយការណ៍សរុប លេខៈ **១៩៣៣/១៩ រ.ប.ក** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀន បានឱ្យដឹងថា ៖ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ មានករណី **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ជិតភ្លើងស្តុបបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា **៤២** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបង្កដោយឈ្មោះ [redacted] **តូច** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ។

២.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខៈ **៥០៣២ "ច" ដ.ដ** ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **តូច** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះពីបទ ចាត់ចែងឱ្យ

**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ជិតភ្លើងស្តុបបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **តូច** បានឆ្លើយនៅគ្រប់តំណាក់កាលនីតិវិធីប្រហាក់ប្រហែលគ្នាថា ៖ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូឌុបទៅជាមួយឈ្មោះ [redacted] **ឡុង** ថាមករកទិញថ្នាំញៀនយកទៅជក់ ដោយចូលគ្នាទិញម្នាក់ ១០.០០០ **(មួយម៉ឺន)** រៀល តែពេលជិះទៅដល់ក្លាន់ពីរមិនទាន់បានទិញថ្នាំញៀនផង ស្រាប់តែសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនប្រហែល ០១ ទៅ ០២ ខែមកហើយ ប្រើប្រាស់ជាមួយឈ្មោះ [redacted] **ឡុង** ។ ខ្លួនទិញថ្នាំញៀនពីមនុស្សមិនស្គាល់ឈ្មោះ នៅម្តុំរ៉ាវទះភ្លើងជិតក្លាន់ពីរនេះតែម្តង នៅពេលឃាត់ខ្លួនសមត្ថកិច្ចមិនបានដកហូតអ្វីពីខ្លួននោះទេ ថ្នាំញៀនក៏គ្មានដែរ។ សមត្ថកិច្ចបានធ្វើតេស្តទឹកនោមលទ្ធផលមានសារធាតុញៀននៅក្នុងខ្លួន។

៤.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡុង** បានឆ្លើយនៅគ្រប់តំណាក់កាលនីតិវិធីប្រហាក់ប្រហែលគ្នាថា ៖ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] **តូច** មករកទិញថ្នាំញៀនយកទៅជក់ ដោយចូលលុយគ្នាម្នាក់ ១០.០០០ **(មួយម៉ឺន)** រៀល តែពេលជិះទៅដល់ក្លាន់ពីរមិនទាន់បានទិញថ្នាំញៀនផង ស្រាប់តែសមត្ថកិច្ច ចាប់ឃាត់ខ្លួនតែម្តង។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនប្រហែល ០២ ទៅ ០៣ ខែមកហើយ ប្រើជាមួយឈ្មោះ [redacted] **តូច** ខ្លួនទិញថ្នាំញៀនពីមនុស្សមិនស្គាល់ឈ្មោះ នៅម្តុំរ៉ាវទះភ្លើងជិតក្លាន់ពីរ ។ នៅពេលឃាត់ខ្លួនសមត្ថកិច្ចមិនបានដកហូតអ្វីពីខ្លួននោះទេ ថ្នាំញៀនក៏គ្មានដែរ ។

៥.តាមលទ្ធផលនៃការធ្វើតេស្តស្វែងរកសារធាតុញៀន ក្នុងកំណត់ហេតុលេខ: ៧០៩ កណហ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៩ មន្ត្រីបច្ចេកទេសបានយកទឹកនោមរបស់ជនជាប់ចោទ ឈ្មោះ [redacted] **តូច** មកធ្វើតេស្តប្រភេទ Test Strip (តេស្តរហ័សសម្រាប់ស្វែងរកសារធាតុញៀនប្រភេទ មេតំហ្វេតាមីន ក្នុងទឹកនោម) ដោយធ្វើតេស្តនៅចំពោះមុខជនជាប់ចោទ និងមន្ត្រីដែលអញ្ជើញចូលរួម ជាលទ្ធផល **វិជ្ជមាន (មានសារធាតុញៀន)** ។

៦.តាមលទ្ធផលនៃការធ្វើតេស្តស្វែងរកសារធាតុញៀន ក្នុងកំណត់ហេតុលេខ: ៧០៨ កណហ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៩ មន្ត្រីបច្ចេកទេសបានយកទឹកនោមរបស់ជនជាប់ចោទឈ្មោះ [redacted] **ឡុង** មកធ្វើតេស្តប្រភេទ Test Strip (តេស្តរហ័សសម្រាប់ស្វែងរកសារធាតុញៀនប្រភេទ មេតំហ្វេតាមីន ក្នុងទឹកនោម) ដោយធ្វើតេស្តនៅចំពោះមុខជនជាប់ចោទ និងមន្ត្រីដែលអញ្ជើញចូលរួម ជាលទ្ធផល **វិជ្ជមាន (មានសារធាតុញៀន)** ។

៧.ឆ្លងតាមការឆ្លើយសារភាពរបស់ជនជាប់ចោទ និង ឆ្លងតាមការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿងឃើញថាមានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថាជនជាប់ចោទ ឈ្មោះ [redacted] **តូច** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តបទល្មើស **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ជិតភ្លើងស្តុបបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ហេតុដូច្នេះគប្បីតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើទៅតាមច្បាប់ ។

៨.ជនជាប់ចោទឈ្មោះ [redacted] **តូច** ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ឡុង** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន មានកាយសម្បទាគ្រប់គ្រាន់ពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិល



Scanned with CamScanner

សង្ស័យថាជននេះមានបញ្ហាវិបល្លាសស្មារតី ក្នុងពេលកំពុងប្រព្រឹត្តបទល្មើសនោះទេ ម្យ៉ាងវិញទៀតជនជាប់ចោទមានលទ្ធភាពអាចពិចារណា និងដឹងយ៉ាងច្បាស់ថាអំពើប្រព្រឹត្តរបស់ខ្លួន គឺខុសទៅនឹងច្បាប់ព្រហ្មទណ្ឌដែលនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមហើយជនជាប់ចោទមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន តាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

៩.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការទៅលើជនជាប់ចោទខាងលើ គឺមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ អាចឱ្យតុលាការលើកយកមកពិចារណាបាន ។

១០.មានពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោ[redacted]តូច ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឡុង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចជិតភ្លើងស្តុបបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>**ហេតុដូច្នេះសម្រេច**</u>

-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] តូច ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឡុង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន ដាក់ពន្ធនាគារក្នុងម្នាក់ៗចំនួន ០២ (**ពីរ**) **ឆ្នាំ** តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ១០ (**ដប់**) **ខែ** ទោសសល់ពីនេះត្រូវព្យួរ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤.000.000៛ (**បួនលាន**) រៀល ដើម្បីបង់ចូលជាថវិការដ្ឋ ។

ពីបទ ៖ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ជិតភ្លើងស្តុបបឹងកក់ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១០៦ មាត្រា ១០៧ មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់ ។

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃច័ន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner